**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៣០/២០ **ក.ប**/ស.ជ.ណ.ន.ព

# សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic សម្រាប់ពលករជំនាញ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

- មណ្ឌលសម្រាប់ការធ្វើតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic មានពីរដូចខាងក្រោម៖

  ១. មណ្ឌលសកលវិទ្យាល័យអន្តរជាតិ ប៊ែលធី (សាខាទួលស្លែង)
    - អាសយដ្ឋាន៖ ផ្ទះលេខ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - លេខទូរស័ព្ទ៖ +855 78 221 222

  ២. មណ្ឌលវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
    - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
    - លេខទូរស័ព្ទ៖ +855 23 966 967 / +855 12 629 768 / +855 15 729 123

- កាលបរិច្ឆេទការធ្វើតេស្ត ៖
    - ចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០
    - នៅថ្ងៃទី១៤ ទី១៥ ទី២០ និងទី២១ ខែវិច្ឆិកា ឆ្នាំ២០២០

- ព័ត៌មានលម្អិតអំពីការចែកពាក្យ និងការចុះឈ្មោះធ្វើតេស្ត សូមចូលមើលគេហទំព័រខាងក្រោម៖

  http://ac.prometric-jp.com/testlist/nc/en/index.html

- ការធ្វើតេស្តចែកជា ៤ផ្នែក (រយៈពេល៦០នាទី)៖

  ១. ពាក្យ (Script and Vocabulary)

  ២. ការសន្ទនា (Conversation and Expression)

  ៣. ការស្តាប់ (Listening Comprehension)

  ៤. ការអាន (Reading Comprehension)។

➢ ការប្រលងតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic ៤ផ្នែក ខាងលើមាន ៦០សំណួរ និងរយៈពេល ៦០នាទី
➢ ការធ្វើតេស្តគឺធ្វើឡើងតាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT Method)
➢ ពិន្ទុដែលជាប់ការប្រលងតេស្តសមត្ថភាពភាសាជប៉ុន JFT-Basic គឺចាប់ពី២០០ពិន្ទុ លើពិន្ទុសរុប២៥០
➢ តម្លៃចុះឈ្មោះធ្វើតេស្ត៖ ២២ដុល្លារ
➢ **ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់មកជាមួយរួមមាន៖**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
- លិខិតឆ្លងដែន ឬ
- ប័ណ្ណបើកបរ

**<u>បញ្ជាក់៖</u>** កាលបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជំងឺកូវីដ-១៩។ ក្នុងករណីមានការប្រែប្រួលណាមួយ ក្រសួងនឹងជូនដំណឹងបន្ថែមទៀត។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងលេខទូរស័ព្ទ +603 76283371 (ប្រទេសជប៉ុន) រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់សុំចុះឈ្មោះធ្វើតេស្តសមត្ថភាពភាសាជប៉ុន ជ្រាបតាមការគួរ។

ថ្ងៃ សុក្រ ៨កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០២០
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**
-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
-ឯកសារ-កាលប្បវត្តិ